**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...០០២......សហវ.ហម

# *សារាចរណែនាំ*

## *ស្តីពីការអនុវត្តន៍ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៥*

យោងតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជសរកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នសរកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីបទបញ្ញាថវិការបស់ខេត្ត ក្រុង និងប្រកាសពីលេខ ០០៦ សហវ.ហម ដល់លេខ ០២៥ សហវ.ហម ចុះថ្ងៃទី១២ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូល និងការបែងចែក ឥណទានថវិកាខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ ៖

### ក. អំពីចំណូល

#### ១. ចំណូលសារពើពន្ធ

ចំពោះមុខសញ្ញាចំណូលសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសំរាប់ ជាគុណប្រយោជន៍នៃថវិកាខេត្ត ក្រុងនោះ ខេត្ត ក្រុងត្រូវជំរុញ និងតាមដានការអនុវត្តន៍គោលនយោបាយពន្ធដារអោយបានត្រឹមត្រូវរបស់មន្ត្រីពន្ធដារ និងត្រូវរួម ចំណែកដាក់ចេញវិធានការជាក់ស្តែងសំរាប់ប្រភេទពន្ធដារនីមួយៗ ដើម្បីតម្រូវអោយអ្នកជាប់ពន្ធ បង់ពន្ធបានត្រឹមត្រូវគ្រប់គ្រាន់ និងទាន់ពេលវេលា។ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ បានអនុញ្ញាតអោយខេត្ត ក្រុងប្រមូលអាករសំរាប់ បំភ្លឺសាធារណៈចំនួន ៣% លើគ្រឿងស្រវឹង និងបារី ដែលលក់នៅក្នុងមណ្ឌលដែនដីរបស់ខ្លួន ដូច្នេះខេត្ត ក្រុងត្រូវជួយជំរុញការអនុវត្តន៍ប្រមូលអាករនេះអោយទទួលបានលទ្ធផលល្អ។

#### ២. ចំណូលមិនមែនសារពើពន្ធ

ចំពោះចំណូលមិនមែនសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសំរាប់ថវិកាខេត្ត ក្រុងនោះ ខេត្ត ក្រុងត្រូវយក ចិត្តទុកដាក់ស្រាវជ្រាវកំណត់មុខសញ្ញាចំណូលដែលត្រូវប្រមូលបង់ចូលរតនាគារអោយអស់ មិនត្រូវទុកចំណូលខ្លះ នៅដោយឡែក សំរាប់ចំណាយដោយឡែកក្រៅពីគំរោងចំណាយប្រចាំឆ្នាំឡើយ ។ ចំពោះចំណូលមិនមែនសារពើពន្ធដទៃទៀត ដែលខេត្ត ក្រុង បានប្រមូលក្រៅពីការអនុញ្ញាតដោយច្បាប់ ក៏ត្រូវបង់ចូលថវិកាខេត្ត ក្រុងដែរ ជៀសវាងទុកចំណូលនោះដោយឡែក សំរាប់ចំណាយដោយឡែក គ្មានតម្លាភាព ។ ចំពោះមុខសញ្ញាចំណូលដែលបានកំណត់រួចហើយ លើក្នុងលក្ខណ្ឌដែលត្រូវប្រមូលតាមវិធីដេញថ្លៃជាសាធារណៈនោះ ត្រូវធ្វើអោយមានតម្លាភាពពិតប្រាកដ មិនត្រូវបង្កើតការដេញថ្លៃតែរូបភាពនោះទេ ទន្ទឹមនោះត្រូវយកចិត្តទុកដាក់ជំរុញការបង់ចំណូលអោយបានត្រឹមត្រូវតាមការកំណត់ដែលមានចែងក្នុងកិច្ចសន្យា ។

## ៣. ចំណូលឧបត្ថម្ភពីថវិការដ្ឋ និងការរៀបចំកម្មវិធីចំណូល ចំណាយ

ចំពោះខេត្ត ក្រុង ដែលត្រូវបំពេញតុល្យភាពដោយការឧបត្ថម្ភពីថវិការដ្ឋ ទោះបីបានកត់ត្រាតួលេខចំណូលឧបត្ថម្ភ ពីថវិការដ្ឋនៅក្នុងគំរោងថវិការបស់ខ្លួនក៏ដោយ ក៏មិនមានន័យថាថវិការដ្ឋត្រូវតែដាច់ខាតឧបត្ថម្ភតាមចំនួននោះទេ ។ ចំណូល ឧបត្ថម្ភពីថវិការដ្ឋ គឺត្រូវពិនិត្យឧបត្ថម្ភជូនខេត្ត ក្រុង ដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃតុល្យភាពថវិការដ្ឋ និងទៅតាមសភាពការណ៍ជាក់ស្តែងនៃការអនុវត្តន៍ចំណូល ចំណាយថវិការបស់ខេត្ត ក្រុង ។

នៅដើមត្រីមាសទី ១ ផ្អែកលើគំរោងថវិកាប្រចាំឆ្នាំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសជូនកម្មវិធីចំណូល ចំណាយរបស់ខេត្ត ក្រុងនីមួយៗ សំរាប់ត្រីមាសទី ១ ហើយនៅចុងត្រីមាសនីមួយៗ ខេត្ត ក្រុងទាំងអស់ (ទាំងខេត្ត ក្រុងបានទទួល និងមិនបានទទួលការឧបត្ថម្ភតុល្យភាពពីថវិការដ្ឋ) ត្រូវផ្ញើកម្មវិធីចំណូល ចំណាយសំរាប់ត្រីមាសបន្ទាប់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសំរេចដែលភ្ជាប់មកជាមួយនូវឯកសារដែលពាក់ព័ន្ធដល់ការអនុវត្តន៍កម្មវិធីនេះ ។ យ៉ាងយូរបំផុតមួយសប្តាហ៍នៃត្រីមាសបន្ទាប់ ក្នុងករណីដែលខេត្ត ក្រុងណា ពុំបានផ្ញើកម្មវិធីចំណូល ចំណាយមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ក្រុងនោះត្រូវអនុវត្តតាមកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសជូន ។

### ៣.១ ចំណូលឧបត្ថម្ភពីថវិការដ្ឋ

ចំពោះចំណូលនេះ ខេត្ត ក្រុងត្រូវធ្វើសំណើសុំឧបត្ថម្ភតុល្យភាពប្រចាំត្រីមាសនីមួយៗ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ។ នៅដើមត្រីមាសទី ១ នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្តល់ថវិកាឧបត្ថម្ភតុល្យភាពជូនខេត្ត ក្រុង ដោយផ្អែកលើមូលដ្ឋាន ៣/១២ នៃគំរោងឧបត្ថម្ភតុល្យភាពប្រចាំឆ្នាំ ដោយមិនបាច់មានការស្នើសុំទេ ។ ដោយឡែកសំរាប់ត្រីមាសទី ២ ទី ៣ និងទី ៤ ខេត្ត ក្រុង ត្រូវធ្វើសំណើសុំថវិកាឧបត្ថម្ភតុល្យភាពនៅខែចុងត្រីមាសមុនសំរាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់មកជាមួយនូវកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស ដែលមានលំអិតតាមខែនីមួយៗ និងចំនួនឱនភាព ដែលចាំបាច់ត្រូវសុំ ឧបត្ថម្ភតុល្យភាព ។ កម្មវិធីចំណូលចំណាយខាងលើនេះ ត្រូវធ្វើលំអិតទៅតាមជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌនៃមាតិកាថវិកា និងត្រូវមានឯកសារជាផ្លូវការសំរាប់បញ្ជាក់អំពីលទ្ធភាពកេណ្ឌប្រមូលចំណូល និងតំរូវការចំណាយពិតប្រាកដដូចជា ៖

- តារាងក្របខ័ណ្ឌមន្ត្រីរាជការ បៀវត្សនិងប្រាក់បំណាច់ប្រចាំខែ និងឯកសារពាក់ព័ន្ធបុគ្គលិកអណ្តែតភ្នាក់ងារជាប់កិច្ចសន្យា (តាមតារាងគំរូភ្ជាប់ជាមួយ)
- ដីកាស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទាន
- របាយការណ៍សរុបចំណូល ចំណាយជាក់ស្តែងរហូតដល់ខែចុងក្រោយ ដោយមានហត្ថលេខាបញ្ជាក់ពីរតនាគារខេត្ត ក្រុង

- តារាងចាំទស្នានចំណូល របស់សាខាពន្ធដារខេត្ត ក្រុង និងរបស់អង្គភាពនានាដែលពាក់ព័ន្ធដល់ការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយមានភ្ជាប់ជាមួយនូវសៀវភៅបន្ទុក កិច្ចសន្យា ឬ ឯកសារដែលបញ្ជាក់អំពីការិយបរិច្ឆេទត្រូវបង់ចំណូល ។

- តារាងចាំទស្នានចំណាយ តារាងចំណាយនេះ ត្រូវរាយលំអិតតាមមាតិកាថវិកានិងគ្រោងតាមខែនីមួយៗ មិនត្រូវធ្វើគំរោងជាតួលេខរួមមួយត្រីមាសឡើយ ។ ចំពោះចំណាយជាគុណប្រយោជន៍របស់ ខេត្ត ក្រុង (ចំណាយដោយឡែករបស់ផ្នែក ជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤) ត្រូវភ្ជាប់មកជាមួយនូវគំរោងចំណាយលំអិតតាមការដ្ឋាននីមួយៗ ដូចជា បំភ្លឺសាធារណៈ និងផ្គត់ផ្គង់ទឹក អនាម័យសុខាភិបាល និងសន្តិសុខការសង្គ្រោះ

ដល់ជនក្រីក្រការរៀបចំថែទាំផ្លូវ ប្រព័ន្ធបញ្ចេញបញ្ចូលទឹក សួនច្បារប្រាំងទន្លេ.....ដែលបានអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ត្រូវភ្ជាប់ជាមួយនូវសៀវភៅបន្ទុក កិច្ចសន្យា និងឯកសារដែលបញ្ជាក់អំពីពេលវេលាត្រូវទូទាត់ ។

**៣.២ ចំណូលឧបត្ថម្ភពីថវិការដ្ឋសំរាប់វិនិយោគសាធារណៈ**

ចំណូលនេះ គ្រាន់តែជាការផ្ទេរឥណទានថវិការដ្ឋសំរាប់អនុវត្តនូវកម្មវិធីចំណាយវិនិយោគសាធារណនៅក្នុងថវិកា ខេត្ត ក្រុង ដូច្នេះក្នុងករណីមានការឧបត្ថម្ភខេត្ត ក្រុង ត្រូវធ្វើសំណើត្រង់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែម្តង ការស្នើនេះ ចែកចេញជាពីរយ៉ាង ៖

**ទី១. ឧបត្ថម្ភសំរាប់ចូលនិធិបដិភាគ**(ជំពូក ៣១ ប្រការ ០២) ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិកាខេត្ត ក្រុង ឬប្រកាសបន្ថែមឥណទាន ត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវគំរោងកម្មវិធីវិនិយោគសាធារណៈនៃ ហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលត្រូវអនុវត្តនៅខេត្ត ក្រុងរបស់ខ្លួន ។

**ទី២. ឧបត្ថម្ភវិនិយោគដោយថវិការដ្ឋ** (ជំពូក ៣១ ប្រការ ០៤) ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិកាខេត្ត ក្រុង ឬប្រកាសបន្ថែមឥណទាន ត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវឯកសារដែលបានធ្វើលទ្ធកម្មសាធារណៈរួចតាមការដ្ឋាននីមួយៗ ។

## ខ. អំពីចំណាយ

**១. ចំណាយចរន្ត** : ចំណាយចរន្តត្រូវអនុវត្តអោយបានម៉ឺងម៉ាត់ ទៅតាមគោលការណ៍និងនីតិវិធីដូចគ្នា នៃចំណាយថវិការដ្ឋដែរពោលគឺ ៖

- អំពីចំណាយបៀវត្សត្រូវអនុវត្តតាមរយៈភ្នាក់ងារបើកផ្តល់ អោយចំពោះបៀវត្សមូលដ្ឋាន និងប្រាក់កំរៃបុគ្គលិកអណ្តែត ភ្នាក់ងារជាប់កិច្ចសន្យា ត្រូវអនុវត្តតាមសេចក្តីសំរេចទទួលស្គាល់របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

- អំពីចំណាយតូចតាច និងចំណាយចាំបាច់បន្ទាន់ គឺត្រូវអនុវត្តតាមរយៈរដ្ឋទេយ្យបុរេប្រទានដែលកំណត់ឡើងដោយដីការបស់ខេត្ត ក្រុង ។ ពេលដកប្រាក់ពីរតនាគារ រដ្ឋទេយ្យករត្រូវមានប័ណ្ណដកប្រាក់ និងលិខិតឧទ្ទេសនាមរបស់អង្គភាព (ពុំចាំបាច់ធ្វើលិខិតស្នើសុំថ្លងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ) ។

- អំពីចំណាយចរន្តផ្សេងៗទៀត គឺត្រូវអនុវត្តទៅតាមនីតិវិធីទូទាត់ត្រង់ជូនអ្នកផ្គត់ផ្គង់ ក្រោយពេលដែលទំនិញ ឬសេវានានា ត្រូវបានអនុវត្តរួចហើយ ។

- ដោយឡែកចំពោះជំពូក ៤១ "ចំណាយមិនបានគ្រោងទុក" ខេត្ត ក្រុងមិនត្រូវអនុវត្តចំណាយជំពូកនេះ ដោយផ្ទាល់ទេ ។ នៅពេលមានតំរូវការចំណាយ ខេត្ត ក្រុងត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបង្វែរឥណទានពីជំពូកនេះ ទៅជាប្រយោជន៍ដល់ជំពូកចំណាយដទៃទៀត ទៅតាមតំរូវការចំណាយជាក់ស្តែងនីមួយៗ ជាពិសេសសំរាប់បំរើនូវការអភិវឌ្ឍន៍ខេត្ត ក្រុង ។

**២. ចំណាយជាមូលធន** : ចំពោះការចំណាយជាមូលធនគឺចែកចេញជាពីរ ៖

**ទី១. ចំណាយសំរាប់ចូលនិធិបដិភាគ** : ក្នុងពេលអនុវត្ត ខេត្ត ក្រុងត្រូវធ្វើអាណត្តិដោយគ្រាន់តែភ្ជាប់តាមនូវគំរោងកម្មវិធីវិនិយោគសាធារណៈនៃហិរញ្ញប្បទានពីក្រៅប្រទេសតែប៉ុណ្ណោះ ។ រតនាគារខេត្ត ក្រុង ត្រូវបើកផ្តល់ឬផ្ទេរឥណទាននេះទៅក្នុងគណនីម្ចាស់ជំនួយនៅរតនាគារខេត្ត ក្រុង ឬធនាគារ (បើមាន) ។

ទី២. **ចំណាយវិនិយោគ** : ចំណាយវិនិយោគ ទោះជាហិរញ្ញប្បទានដោយថវិកាខេត្ត ក្រុង ឬហិរញ្ញប្បទានដោយថវិការដ្ឋឧបត្ថម្ភក៏ដោយ គឺត្រូវតែបំពេញបែបបទ និងអនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន ។

៣. **ចំណាយបន្ថែមលើសពីគំរោងចំណាយថវិកាខេត្ត ក្រុងប្រចាំឆ្នាំ** : យោងប្រការ ១២ នៃប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង បានចែងថា ឲ្យនៅក្នុងឆ្នាំថវិកា ប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់ខេត្ត ក្រុង បានកើនលើសពីគំរោងចំណូលប្រចាំឆ្នាំដែលបានគ្រោងទុកនោះ ឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមកំរិតចំណូលលើសដែលរតនាគារខេត្ត ក្រុងបានបញ្ជាក់រួចហើយ ។

ដូច្នេះ នៅត្រីមាសទី ៤ ខេត្ត ក្រុងត្រូវធ្វើការវាយតម្លៃការអនុវត្តចំណូលប្រចាំឆ្នាំរបស់ខ្លួន ដោយមានមូលដ្ឋានជាក់លាក់ដែលអាចប្រមូលចំណូលបានយ៉ាងពិតប្រាកដ រួចប្រៀបធៀបជាមួយគំរោងចំណូលប្រចាំឆ្នាំ ។ ប្រសិនបើមានចំណូល លើសពីគំរោងចំណូលប្រចាំឆ្នាំ ខេត្ត ក្រុងអាចស្នើសុំបន្ថែមលើគំរោងចំណាយប្រចាំឆ្នាំ សំរាប់ចំណាយជាគុណប្រយោជន៍របស់ខេត្ត ក្រុង ដែលជាចំណាយសំរាប់វិនិយោគអភិវឌ្ឍន៍ខេត្ត ក្រុង ហើយខេត្ត ក្រុងត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវគំរោងចំណាយលំអិតតាមការដ្ឋាននីមួយៗផង ។

## គ. ការធ្វើវិសហមជ្ឈការ លទ្ធកម្មសាធារណៈ

ក្នុងស្មារតីយកចិត្តទុកដាក់អនុវត្តកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ និងដើម្បីលើកកំពស់ការទទួលខុស ត្រូវរបស់ឯកឧត្តមអភិបាលខេត្ត ក្រុង ក្នុងការអនុវត្តន៍ថវិការបស់ខ្លួនអោយបានទាន់ពេលវេលាក្នុងឆ្នាំ ២០០៥ នេះ ជាជំហ៊ានសាកល្បង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចេញសេចក្តីប្រកាសស្តីពីការធ្វើវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ ជំហ៊ានដំបូងជូនក្រសួងស្ថាប័នខេត្ត ក្រុងនិងសហគ្រាសសាធារណៈ ដូច្នេះ អភិបាលខេត្ត ក្រុងត្រូវយកចិត្តទុកដាក់អនុវត្តកិច្ចលទ្ធកម្មអោយបានត្រឹមត្រូវតាមសេចក្តីប្រកាសនេះ ។

## ឃ. ការបង្វែរឥណទានផ្ទៃក្នុងជំពូក

យោងប្រការ ១៣ វាក្យខ័ណ្ឌទី ២ នៃប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង បានចែងថាឲ្យការបង្វែរពីប្រការមួយទៅប្រការមួយ ពីកថាខ័ណ្ឌមួយទៅកថាខ័ណ្ឌមួយ និងពីវាក្យខ័ណ្ឌមួយទៅវាក្យខ័ណ្ឌមួយ ដែលនៅក្នុងជំពូកតែមួយត្រូវធ្វើឡើងដោយដីការបស់អភិបាលខេត្ត ក្រុង បន្ទាប់ពីមានការឯកភាពរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ.....។ ប៉ុន្តែខេត្ត ក្រុងមិនត្រូវបង្វែរឥណទានពីជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤ (ចំណាយដោយឡែករបស់ផ្នែក) ទៅចំណាយនៅកថាខ័ណ្ឌផ្សេងៗទៀតនៃជំពូក ១១ ដែលជាហេតុនាំអោយចំណាយសំរាប់ដំណើរការរដ្ឋបាលមានការកើនឡើង ហើយចំណាយសំរាប់ជាគុណប្រយោជន៍ ខេត្ត ក្រុង មានការថយចុះនោះទេ ។ ប្រសិនបើមានករណីចាំបាច់ខេត្ត ក្រុង ត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងការអនុវត្តន៍ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង ត្រូវអនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធីហិរញ្ញវត្ថុ និងទៅតាមគំរោងនៃការដ្ឋាននីមួយៗ ដែលខេត្ត ក្រុងបានលើកក្នុងផែនការអភិវឌ្ឍន៍ និងមានការពិភាក្សាឯកភាពពីក្រសួងមហាផ្ទៃរួចហើយ ។ នៅពេលអនុវត្តប្រសិនបើខេត្ត ក្រុងមានការចាំបាច់ត្រូវផ្លាស់ប្តូរគំរោងចំណាយ

នៃការដ្ឋានណាមួយនោះ ខេត្ត ក្រុងត្រូវស្នើសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមុនទើបអាចចាប់ផ្តើមអនុវត្តគំរោងចំណាយសំរាប់ការដ្ឋានថ្មីបាន ។

ខាងលើនេះ គឺជាការណែនាំបន្ថែមក្នុងកិច្ចប្រតិបត្តិការថវិកាខេត្ត ក្រុងអោយចំទិសដៅនិងមានប្រសិទ្ធភាព សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដោយឡែកប្រកាសណែនាំស្តីពីកិច្ចប្រតិបត្តិការអនុវត្តថវិកាខេត្ត ក្រុង លេខ ២០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលមិនផ្ទុយនឹងប្រកាសនេះ នៅតែរក្សាសុពលភាពដដែល ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូនៈ**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

(ដើម្បីជូនជ្រាប)

- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត ក្រុង
- គ្រប់រតនាគារខេត្ត ក្រុង
- គ្រប់សាខាពន្ធដារខេត្ត ក្រុង

(ដើម្បីអនុវត្ត)

- ឯកសារ-កាលប្បវត្តិ